កំណាព្យ

# បុប្ផាខ្មៅ

## ជីវិតនិស្សិត

(សម្រង់អត្ថបទ)

បោះពុម្ពលើកទី១
ចំនួន ២.៥០០ក្បាល
ខែវិច្ឆិកា ១៩៧០

គយ សារុន

រក្សាសិទ្ធិ

# ជំរាបអ្នកអាន

នេះជាលើកដំបូង ដែលខ្ញុំផ្សាយអត្ថបទស្នាដៃ។

តាមពិត ខ្ញុំបានចាប់ផ្ដើមរៀនសរសេរតាំងពីឆ្នាំ ១៩៥៨ គឺតាំងពីខ្ញុំនៅរៀនថ្នាក់ទី២ នៃវិទ្យាល័យស៊ីសុវត្ថិ (បច្ចុប្បន្នវិទ្យាល័យភ្នំដូនពេញ) ។

ស្នាដៃកំណាព្យទី១របស់ខ្ញុំឈ្មោះ **ជីវិតនិស្សិត** ត្រូវបានជាប់លេខ៣ក្នុងការប្រឡងប្រជែងអក្សរសាស្ត្រឆ្នាំ ១៩៥៩ ខាងក្រសួងអប់រំជាតិ។ ខ្ញុំមិនបានបោះពុម្ពស្នាដៃនោះទេ ព្រោះយល់ថាគំនិតខ្ញុំនៅខ្ចីណាស់ ហើយខ្ញុំច្រើនសរសេរពីរឿងផ្ទាល់ខ្លួនផង។

ជោគជ័យដ៏តូចមួយនោះ គ្រាន់តែបានបណ្ដុះចិត្តខ្ញុំឲ្យមានសេចក្ដីសង្ឃឹមក្នុងការសរសេរប៉ុណ្ណោះ។ ខ្ញុំបានចិញ្ចឹមចិត្តនោះជានិច្ច រហូតមកដល់ឆ្នាំ១៩៦៥ ទើបខ្ញុំចង់សាកល្បងសរសេរម្ដងទៀត។

កំណាព្យឈ្មោះបុប្ផាខ្មៅ ក៏កើតមានរូបរាងឡើង ហើយបានជាប់លេខ២ ក្នុងការប្រឡងអក្សរសាស្ត្រឆ្នាំ ១៩៦៧ ។ ប៉ុន្តែទោះបីជាឱ្យជាប់ដូច្នេះហើយក៏ដោយ មេប្រយោគកែវិញ្ញាសារបស់ខ្ញុំ មានលោកឈឹម ស៊ុម ,

ឈូក ម៉ៅ ជាដើមដែលខ្ញុំបានទៅជួបក៏បានសម្ដែងនូវការបារម្ភខ្លះដែរ។

ខ្ញុំត្រូវគិតច្រើនក្នុងរឿងនេះ ...

ហើយក៏សម្រេចចិត្តមិនផ្សាយស្នាដៃនេះមួយទៀត, គ្រាន់តែបានបង្ហាញមិត្តភក្តិជិតដិតដែលចង់ឃើញប៉ុណ្ណោះ។

ឥឡូវនេះ ដោយសេរីភាពក្នុងការសរសេរក៏មានហើយ ឯមិត្តភក្តិក៏ចេះតែសួររក ខ្ញុំយល់ថាមិនគួរទុកចោលស្នាដៃនេះតទៅទៀតទេ។ ម្យ៉ាងទៀត ខ្ញុំយល់ថា ការដែលក្រសួងអប់រំជាតិក្ដី សមាគមអ្នកនិពន្ធខ្មែរក្ដី ខំរៀបចំការប្រឡងប្រជែងអក្សរសាស្ត្រ និងការដែលលោកអ្នកសប្បុរសខំផ្ដល់អំណោយដល់ជ័យលាភី មិនមែនគ្រាន់តែចង់លើកទឹកចិត្តអ្នកសរសេរប៉ុណ្ណោះទេ គឺច្បាស់ជាមានឧត្ដមគតិខ្ពង់ខ្ពស់ចង់ឱ្យអក្សរសាស្ត្រខ្មែរលូតលាស់ដើម្បីជាប្រយោជន៍ទូទៅ។ បច្ចុប្បន្ននេះ ខ្ញុំយល់ថាជាឱកាសដែលខ្ញុំត្រូវបម្រើឧត្ដមគតិនេះហើយ ទោះបីបានច្រើនក្ដី តិចក្ដី។

ជាមួយនឹងស្នាដៃទី២ ឈ្មោះបុប្ផាខ្មៅ នេះ ខ្ញុំសូមជូនស្នាដៃទី១ឈ្មោះជីវិតនិស្សិតផងដែរ ប៉ុន្តែគ្រាន់តែធ្វើ

សម្រង់អត្ថបទខ្លះដែលខ្ញុំនៅស្រឡាញ់ហើយមិនចង់ឱ្យបាត់បង់។

X X X

ក្នុងការផ្ដើមផ្សាយស្នាដៃជាដំបូងនេះ ខ្ញុំសូមផ្ញើជូនតាមរយៈសៀវភៅនេះ នូវអំណរគុណដ៏ស្មោះរបស់ខ្ញុំចំពោះ ៖

-ក្រសួងអប់រំជាតិ ដែលបានបណ្ដុះសេចក្ដីសង្ឃឹមឱ្យខ្ញុំជាដំបូងក្នុងការសរសេរ ;

-សមាគមអ្នកនិពន្ធខ្មែរដែលបានបម្រើវប្បធម៌អក្សរសាស្ត្រខ្មែរពិតៗ ;

-លោកអ្នកសប្បុរសដែលបានធ្វើអំណោយដល់ជ័យលាភី ដើម្បីការលូតលាស់នៃអក្សរសាស្ត្រខ្មែរ ;

-អ្នកសរសេរផ្សាយស្នាដៃមុនៗខ្ញុំទាំងអស់ ដែលស្នាដៃរបស់លោកបានជាពន្លឺដល់ខ្ញុំ ;

-លោក ញូង សឿង, ប៉ាយ ប៊ុក, កេង វ៉ាន់សាក់ ដែលនាំឲ្យខ្ញុំស្រឡាញ់កំណាព្យ , ចេះកំណាព្យ, យល់កំណាព្យតាមរយៈទស្សនាវដ្ដីមិត្តសាលាបាលី , កម្ពុជសុរិយា, សៀវភៅសកុន្តលា, ចិត្តក្រមុំ, គុកកាមកិលេស ;

-លោក ឈឹម ស៊ុម,  ឈូក ម៉ឺង ម៉ៅ,  ហូ តុង ហូ ដែលបានពិនិត្យស្នាដៃខ្ញុំ,  សរសើរខ្ញុំ,  រិះគន់ខ្ញុំ និងឱយយោបល់ល្អៗ ដល់ខ្ញុំក្នុងការសរសេរ។

X X X

ជាបញ្ចប់នេះ ខ្ញុំអរគុណប្អូន ឃុន ស្រ៊ុន ដែលបានសរសើរស្នាដៃខ្ញុំ តាមសារពត៌មាន និងតាមសៀវភៅគំហើញ លេខ២ លេខ៣ ហើយថែមទាំងយកចិត្តទុកដាក់ជួយចាត់ចែងបោះពុម្ពសៀវភៅនេះទៀតផង។

**គយ សារុន**

១០-១១-៧០

## ឈ្មោះអត្ថបទ


១-បុព្វបទ........................................

២-ឱដើមអម្ពិលទឹក................................

៣-«បទុមសុរិយា» ផ្សាយរូប.........................

៤-ទំព័រសៀវភៅ, ទំព័រជីវិត.........................

៥-ស្ទួនផឹត..........................................

៦-សីលធម៌សុំញ៉ម..................................

៧-សុរិយាក្ដៅខ្លាំង....................................

៨-សំណើចចំអកនៃទឹកប្រាក់.........................

៩-វិលវិញឬអូន.......................................

១០-ខ្ញុំតាមមិនទាន់.................................

១១-អក័ព្វកំលោះស្រុកស្រែ.........................

១២-ប្រតិភូក្បត់ពូជ.................................

១៣-ក្រឡាស់ចិត្តទេដឹង.............................

១៤-ឲ្យខ្ញុំសប្បាយម្ដេចកើត..........................

១៥-នគរភ្លើងប្លែក..................................

១៦-វិថីក្រមអ៊ូ........................................

១៧-តិចឬច្រើន.......................................

១៨-ព្រះសង្ឃនិមន្តបិណ្ឌបាត្រ.........................
១៩-សម្រាកមួយភ្លែត..................................
២០-រកស្ងប់គេថាចាញ់...............................
២១-អាសូរដើមដូង.................................
២២-ស្ពាយដូងចន្ទ្រា................................
២៣-ជីវិតនិស្សិត.....................................
២៤-នឹកផ្ទះ.........................................
២៥-លាការសិក្សា..................................
២៦-សម្រេចចិត្ត.....................................

# បុព្វបទ

ប្រហែលជាខ្ញុំវង្វេងទេដឹង បានជាឃើញការស៊ីផឹកសប្បាយនៅតាមផ្ទះបារ ខ្ញុំចេះតែនឹកគិតទៅដល់ការស្រេកឃ្លានខ្វះខាតនៃអ្នកក្រខ្សត់ , ឃើញយុវសិស្សសាលាខ្លះហ៊ឺហា ហក់លោតរាំរែក ខ្ញុំគិតទៅដល់យុវជនខ្លះទៀតដែលស្លៀកពាក់ខោអាវចាស់ៗ ជួនកាលមានប៉ះដោយកន្ទែល ខ្លះប្រដាប់ប្រដារៀនសូត្រ ខ្លះលុយបង់សាលាឬលះបង់ការសិក្សាតែម្តង , ឃើញផ្ទះថ្មធំៗ រថយន្តថ្លៃៗ ខ្ញុំនឹកឃើញទៅដល់ការខ្វល់ខ្វាយរបស់មនុស្សដើម្បីរកវត្ថុទាំងនោះ ដោយជួនកាលលែងទាំងគិតគូរដល់ការត្រូវ-ខុស, ល្អ-អាក្រក់ទៀតផង។

ខ្ញុំឃើញអ្វីៗទាំងនោះ ដូចដែលអ្នកនិពន្ធនៃ "វិមាននរក" ឃើញសម្លៀកបំពាក់ស្រីបារជាក្រដាសប្រាក់ ២០០, ៥០០ ហើយគឺប្រាក់នេះ ដែលអ្នកក្ររកស៊ីបែកញើស ហូរញើស ច្រើនថ្ងៃខែទំរាំនឹងឈោងចាប់បានចំណែកឯ អ្នកមាន ឬអ្នក "រកបានងាយ" គេបែរជាយកទៅពង្រាយចោលទៅវិញ។

តែប្រសិនបើខ្ញុំមិនវង្វេងទេនោះ នុ៎ះគឺមកតែពីខ្ញុំធ្លាប់រស់នៅក្នុងទឹក-ផុក នៃស្រុកស្រែ, ធ្លាប់ចិញ្ចឹមជីវិតដោយសារបាយបាត្រព្រះសង្ឃដើម្បីរៀនសូត្រ, ធ្លាប់ចាកចោលដើងម៉ាវិទ្យាល័យទាំងទឹកភ្នែក ហើយបើយ៉ាងតិចណាស់ ក៏ខ្ញុំមិនចង់ឃើញយុវជនដែលកើតក្នុងត្រកូលខ្សត់ជួបនឹងឧបសគ្គគ្រប់បែបគ្រប់យ៉ាង មិនអាចនឹងរៀនសូត្រកសាងអនាគតឲ្យសមតាមប្រាជ្ញាស្មារតីរបស់ខ្លួននោះឡើយ។

គ.ស.

# ឱ្យដើមអម្ពិលទឹក

១- គេកាត់គេច្រឹបគេរក្សា
ស្អិតស្អាងកាយាឲ្យឥតហ្មង
ពីខាង ពីលើ ផ្ទើរបង
អ្នកផងសរសើរអម្ពិលទឹក ។

២- ថាជារុក្ខជាតិមានវាសនា
គេរាប់ប្រើការបានសន្ធឹក
មានដើមមានមែកបន្ទាញឹក
សន្ធឹកក៏ស្រស់រស់យូរយារ ។

៣- តែស្រស់តែស្អាតតែត្រឹមត្រង់
រូបខ្លួននេះសម្រាប់នរណា ?
សម្រាប់អម្ពិលទឹករុក្ខា ?
ឬថាសម្រាប់មនុស្សវិញទេ ? ។

៤- ដើមណាដែលរស់តាមធម្មជាតិ
លូតលាស់តាមមាឌមែកទន់ទេរ
សារិកាច្រៀងច្រែបំពេ
ផ្កាផ្លែរាំរេតាមសូរខ្យល់ ។

៥-	ឯដើមឈើរត្រៀបតម្រៀបផ្លូវ
សមគួរល្អគន់ពន់ពេកសល់
តែកំរើកដែកទ្រៀដល់
បានផលដាច់កត្រដររស់ ។

៦-	រស់រាប់ខែឆ្នាំចាំជីវិត
ក្រិនក្រៀមក្រពឹតឥតកម្ពស់
យាមផ្ទះឲ្យគេទទេសោះ
មានឈ្មោះតែត្រង់គេថាល្អ ។

៧-	លុះថ្ងៃដែលប្រាក់កាសគេដល់
គេកាប់គ្មានសល់ពូជទុកត
គេគាស់ទាំងឫសចាក់គ្រឹះថ្ម
គេសរសើរល្អរបងដែក ។

ភ្នំពេញ ១៨ មេសា ១៩៦៥

## «បទុមសុរិយា»ផ្សាយរូប

១-បទុមសុរិយា ផ្សងរូបប្រាថ្នា
រើសរកស្វាមី បានព្រះជិនវង្ស
តាមរករូបស្រី ដល់ក្រុងអសុរី
រួមរស់ស្នេហា ។

២-គ្រមុំសម័យ រាងរៀវច្រវៃ
បង្ហាញកត្រា ញញឹមប្រិមប្រិយ
លើក្របទស្សនា- វដ្ដី កាលណា
ខ្ញុំលួចកើតទុក្ខ ។

៣-ខ្ញុំសែនស្នេហា ចង់ផ្សងវាសនា
ឱ្យបានជួបមុខ ទាស់ពីគ្មានឫទ្ធិ
ឬគ្មានទ្រព្យស្ដុក ក្រែងស្រីមិនសុខ
ចិត្តចង់ស្នងស្នេហ៍ ។

៤-ម្យ៉ាងទៀតរូបស្រី ផ្សាយពេញផែនដី
បុរីនៃខ្មែរ មិនតែរូបមួយ
ខ្ញុំព្រួយគ្មានល្វែ ក្រែងមានគេដែរ
ចង់ចិត្តប្រចណ្ឌ ។

៥-នាំកើតចប្បាំងគ្នា ដូចជាក្រុងមារ
យក្សសាលីកណ្ឋា អួតអាងពល់ខ្លួន
គុំក្ខួនដុកដាន់ ខ្ញុំមិនក្ខួចកាន់
សូមដកខ្លួនថយ ។

ភ្នំពេញ ១៩ មេសា ៦៨

## ទំព័រសៀវភៅ

### ទំព័រជីវិត

១-	ពេលដែលខ្ញុំបើកទស្សនា-
វដ្ដី កាលណាខ្ញុំសប្បាយ
មើលរូបភ្ញើតភ្ញើនភ្លេចឃ្លានបាយ
រីករាយស្រស់ស្រាយហក់តាមខ្យល់។

២-	មើលឡានចេញថ្មីល្បីថាឆើត
ខ្នងវែងរាងស្មើតទើបមកដល់
បើត្រូវឆ្នោតធំសមលែងខ្វល់
ទិញមួយហើយសល់លុយដើរលេង។

៣-	មើលម៉ូដទំនើបធ្វើសក់ថ្មី
ទឹកមុខលោកស្រីស្រស់ថ្វាឈ្វេង
ថតបែរមុខក្រោយថែមស្ដាំឆ្វេង
ខ្ញុំមុខជាគេងស្រមៃហើយ ! ។

៤-	មើលតារាឯកនៃភាពយន្ដ
ល្អគយល្អគន់ណាស់លោកអើយ
ចេះធ្វើឫកពាចេះឆ្លងឆ្លើយ
ឃើញហើយជាប់ចិត្តឥតចង់ឃ្លាត ។

៥-	មើលការប្រឡងភាពសង្ហា
សង្ហាអស្ចារ្យថែមឡានទៀត
ធ្វើឫកធ្វើពាងចែកជូនញាតិ
បំណាច់ខំធ្មៀតមកពីឆ្ងាយ ។

* * *

៦-	ក្នុងរូបអ្វីៗសុទ្ធតែល្អ
ក្លឹង្គខ្មៅអាចសទៅវិញបាន
ខ្ញុំចង់មើលរូបទាំងប៉ុន្មាន
កំសាន្តសប្បាយឆ្ងាយជីវិត ។

ក្រុងតាកែវ ២១ សីហា ៦៥

## សួនចរិត

១-　　រងំៗមនុស្សជុំជិត
ជីវិតភ្លើតភ្លើនភ្លេចក្នុងបារ
បទភ្លេងល្វេងល្ងើយដាស់កាមា
សួនច្បារផ្ការីកពេលរាត្រី ។

២-　　ផ្ការីកស្ពុងៗក្នុងភ្លើងពណ៌
អប្សរវេរាំតាមតន្ត្រី
ចម្រៀងល្ហិមល្ហែមផ្អែមសម្តី
ស្រស់ស្រីនាងជាទេពកញ្ញា ។

៣-　　កំសាន្តក្នុងសួនទិព្វវិមាន
ចិត្តគ្មានកង្វល់ដល់ទុក្ខា
រសាត់បាត់ហើយរឿងខ្មោចផ្សា
ចិន្តាចាំចងតែថ្ងើមថ្ងៃ ។

៤-　　ភ្លេចភ្លាំងអស់ហើយការសិក្សា
ភ្លេចហើយគ្រួសារដាប់ជើងដៃ
ភ្លេចហើយទុក្ខសោកអ្នកដទៃ
គិតលៃម្តេចបានប្រាក់រាំបារ ។

៥-	អ្នកណាផាប់រស់អ្វីក៏ដោយ
គិតឲ្យតែអញបានហ៊ឺហា
ផឹកស៊ី ស៊ីផឹកដឹកសង្ហា
កំសាន្តសួនច្បារផ្កាផង់ផឹត ។
ភ្នំពេញ ២៤ មិថុនា ៦៥

## សីលធម៌សុំញ៉ាម

១- ផ្ទះថ្មល្អហួសពីការស្មាន
ក្បែរផ្ទះមានឡានចតសេសសល់
ម្ចាស់ផ្ទះឈរស្ញែតមើលមកថ្កល់
ចុះផលបុណ្យអ្វីរបស់គេ ! ។

២- ឡានតូចថ្មីចែសបើកដំបូល
ចេញចូលលូនលេងគ្មានទំនេរ
ថ្ងៃល្ងាចលោកប្រុស-ស្រីទាំងទ្វេ
សង្ហាម៉្លេះទេគេធ្វើអ្វី ? ។

៣- ទំនិញទំនើបពីបរទេស
សុទ្ធល្អវិសេសផុតដែនដី
គេតែងនិយមទាំងប្រុសស្រី
ធ្វើអ្វីបានប្រាក់ទិញដូចចិត្ត ?

៤- ភាពយន្តទំនើបបង្ហាញច្បាស់
ឃើញណាស់តែអ្វីដែលប្រណីត
ខ្លួនក្រចិត្តលួតហួសកំហិត
តើគិតម្តេចផ្តាប់ស្កប់តណ្ហា ?

៥-	បារមានហូរហែរពេញទីក្រុង
រាំឱបចិត្តស្ទុងក្នុងកាមា
គិតម្តេចឲ្យតែបានស្រីស្រា
នរណារស់ស្លាប់កុំខ្ចីខ្វល់!

៦-	រដូវមួយណាក៏ផ្កាស្រស់
ផ្ការីកទាំងអស់ឥតសេសសល់
ឲ្យតែផ្កាប់ចិត្តផ្កាជិតដល់
ខ្វះលុយកុំធ្វល់ចៀសឲ្យឆ្ងាយ!ៗ

៧-	ផ្ទះថ្ម, ឡាន, កុន, បារ, ស្រស់ស្រី
បានសួគ៌លោកិយសែនសប្បាយ
សង្ស័យម្រាក់ខែម្តេចគ្រប់ចាយ
ត្រូវតែខ្វល់ខ្វាយខំ «រកស៊ី»!ៗ

៨-	ឱសីលធម៌អើយ! អ្នកកុំប្បាំង
តតាំងម្តេចឈ្នះធោមនារី
អញ្ជើញដកខ្លួនចូលគម្ពីរ
ទុកទីជូនទៅទ័ពតណ្ហាៗ

ភ្នំពេញ ២៨ មិថុនា ៦៥

# សុរិយាក្តៅខ្លាំង

១-សុរិយាល្ងាចថ្ងៃ ទន្សោងគោព្រៃ
រកស៊ីដើរភ្នំ តូចស៊ីដោយតូច
ធំស៊ីដោយធំ រកស៊ីដើរភ្នំ
ល្បាស់ព្រេចខ្ទីៗ ។

២-សុរិយាល្ងាចថ្ងៃ យុវជនសម័យ
ចង់ធ្វើមន្ត្រី ព្រោះឃើញគេមុន
ប្រពន្ធពីរបី ផ្ទះថ្មឡានថ្មី
មិនបាច់ខិតខំ ។

៣-សុរិយាល្ងាចថ្ងៃ មនុស្សលោកសម័យ
យកលុយជាធំ លុយជាចៅហ្វាយ
ប្រសើរឧត្តម ដឹកក្បាលឱ្យខំ
និយមតែលុយ ។

ភ្នំពេញ ១៣ កក្កដា ៦៥

# សំណើចចំអកនៃទឹកប្រាក់

១-　　សាមគ្គី, សុចរិត, យុត្តិធម៌
មនុស្សធម៌, សីលធម៌, «ធម៌» ច្រើនណាស់
សរសេរហូរហៀរលើក្រដាស
ស្តាប់ឮក្រៃក្រាស់ក្នុងសម្តី　　ៗ
២-　　«ធម៌»នេះចេញមុខអើតតាមទ្វារ
បង្ហាញឫកពាស្រស់ប្រិមប្រិយ
រាប់រក«មិត្តភាព»រក«មេត្រី»
សេពគប់«ប្រណី»គប់«ករុណា»　　ៗ
៣-　　ខាងក្នុង«ទឹកប្រាក់»វាសប្បាយ
លួចមើលក្អាកក្អាយចំអកថា
«អាប្រាក់!អញនេះហើយខ្លាំងក្លា
សោយរាជ្យចេស្តា លើក្បាលមនុស្ស» ៗ

ភ្នំពេញ ៤ កក្កដា ៦៥

«ខលខញ្ញឬអូន?»

១. តូច-ធំ ធំ-តូច ស្តួច-រីកសាយ
ចង្អៀត-ទូលាយ រួចចង្អៀត
វែង-ខ្លី ខ្លី-វែង រួចខ្លីទៀត
រួចបង្ហាញជឿតឱ្យច្បាស់ការ ។

២. ពីដើមមនុស្សស្រាតរួចចេះប៉ឹង
រួចប្រឹងដេរស្លៀកបិទកាយា
ស្លៀកពាក់ជុំជិតរឹតអាត្មា
យល់ថាបែបហ្នឹងទើបហៅល្អ ។

៣. ឥឡូវយល់ថាវែងលែងសម
តាំងខំរៀលរះបញ្ចេញក
បង្ហើចដល់ភ្លៅនៅបន្ត
ចំហថែមទៀតជូនកំសាន្ត ។

៤. យូរទៅប្រហែលជាគេប៉ឹង
ឬស្រាតទេដឹង?មិនហ៊ានស្មាន!
យ៉ាងណាក៏ដោយឱ្យតែបាន
តាមដានសម័យថ្មីឱ្យទាន់ !

ភ្នំពេញ ១២ កក្កដា ៦៩

# ខ្ញុំតាមមិនទាន់

១- កញ្ឆែច! កញ្ឆែច! ក្មេងសម័យ
កន្ទ្រាក់សរសៃឲ្យរាំរែក
អន្ទងបេះដូងឲ្យយំយែក
ហាស្រែករកស្រីស្រៀវកាមា ។

២- គេឱប គេរឹត គេត្រកង
បែរមុខវិលខ្នងពត់កាយា
គេងើប គេមុជ ក្រោមហត្ថា
ហ្នឹងហើយសួគ៌ានាលោកិយ ។

៣- កុំអួសដៃខ្ញុំធ្វើអ្វីមិត្ត
រាំចុះកុះគិតខ្ញុំធ្វើអ្វី!..
ខ្ញុំមិនចេះរាំក្បាច់ខ្មែរថ្មី
ព្រោះអីខ្ញុំដើរមិនទាន់គេ ។

៤- និស្ស័យនៃខ្ញុំអស់ផ្លូវកែ
ខ្ញុំកើតនៅស្រែឥតចេះទេ
ខ្ញុំរស់នៅវត្តស្ងួតបំពេ
ហ៊ានរាំលោកជេរវាយបែកខ្នង ។

៥-	កំហុសយ៉ាងធំ! ខ្ញុំមិនកែ
ទើបងើបពីស្រែស្គាល់ក្រុងម្តង
ទើបចេញពីវត្តផុតរបង
ម្តេចឡើយប្រឡងរាំញ័រញោក់ ។
៦-	កំហុសយ៉ាងធំ! ខ្ញុំមិនកែ
ខ្ញុំខ្មែរភ្លេចស្រែរាំកន្ទ្រាក់
ខ្មាសម៉ែ-ឪ-មា-មីង-មិត្តភ័ក្តិ
ខ្មាសបាយបាត្រស្រាក់ខ្មាសខ្លួនឯង។

ភ្នំពេញ ១៨ មេសា ៦៥

# អភ័ព្វកំលោះស្រុកស្រែ

១-	ពីដើមនៅស្រុកស្រែចម្ការ
ស្នេហាសុខដុមតិរម្យណាស់
ក្រមុំកំលោះស្មោះស្ម័គ្រច្បាស់
ទាំងចាស់ទុំក៏ព្រមល្មមចិត្ត ។

២-	ស្រឡាញ់គ្នាពិតឥតបែកបែរ
ឥតប្រែប្រួលប្រាសផ្តាសចោលមិត្ត
គិតតែរកស៊ីសាងជីវិត
សុចរិតត្រឹមត្រូវសាងក្តីសុខ។

៣-	ឥឡូវក្រមុំចម្ការស្រែ
ចិត្តប្រែចោលកំលោះក្នុងស្រុក
ខ្ជិលដាំដកស្ទូងចង់ស្រណុក
ចាក់ស្មុគរកស្ម័គ្រអ្នកប្រាក់ខែ។

៤-	កំលោះស្រុកស្រែបែរអន់អៀន
គ្មានបុណ្យស័ក្តិធ្លាក់ភ្លូវស្រែ
ម្តេចឡើយគេនឹងមកស្និទ្ធស្នេហ៍
ម៉្លោះហើយត្រូវតែរស់ក្រៀមក្រំ។

ភ្នំពេញ ២៥ មិថុនា ៦៥

# ប្រតកូក្បត់ពូជ

១- អ្នកក្រត្រដរឲ្យកូនរៀន
ខំប្រឹងស្ទើរលៀនភ្នែកគ្រប់គ្នា
លក់គោក្របីជ្រូកមាន់ទា
ដីស្រែចម្ការសឹងមិនសល់។

២- កូនខ្លះផ្តេសផ្តាសមិនខំរៀន
ថែមហ៊ានយកលុយម៉ែឪផ្តល់
ចាយវាយហ៊ឺកហ៊ាក់ហក់តាមខ្យល់
មិនមានគិតដល់ញើសឪម៉ែ។

៣- កូនខ្លះគ្រាន់បើខាងរៀនសូត្រ
ស្ទុះលូតរបូតផុតដីស្រែ
ធ្វើការរាជការបានប្រាក់ខែ
ប៉ុន្តែភ្លេចអស់រឿងក្រីក្រ។

៤- ភ្លេចពូជពណ៌ពង្សវង្សអធន
ដែលរងទុក្ខធ្ងន់មកច្រើនត
ត្រូវគេព្រួតគ្នាប្រចបាច់ក
ត្រដររកខ្យល់ចាំតែស្លាប់។

៥-	អ្នកក្របញ្ជូនឱយមករៀន
ឲ្យមានតម្រិះចេះប្រញាប់
ភ្នែកភ្លឺឃើញច្បាស់ឲ្យដាស់ប្រាប់
ម្តេចឡើយក្រឡាប់ក្បត់ពូជឯង។

៦-	បែរជាព្រួតដៃនឹងអ្នកខ្ពស់
ទ្រគោះប្រឆាំងច្បាំងកំហែង
ថាក្រព្រោះខ្ជិលមិនប្រឹងប្រែង
ថាកម្មតាក់តែងពីព្រេងនាយ។

៧-	បើតែម៉្លឹងៗអ្នកខ្សោយខ្សត់
ប្រាកដជាគ្មានផ្លូវដោះស្រាយ
គេក្បត់ខ្លួនអស់ព្រោះជិនណាយ
ព្រោះគេសប្បាយភ្លេចពូជពណ៌។

ភ្នំពេញ ២៤ កក្កដា ៦៥

# ក្រឡាស់ចិត្តទេដឹង?

១-	ខ្លួនក្រចិត្តខ្ញុំក៏អ្នកក្រ
ឃើញមិត្តពលករខ្ញុំអាណិត
ឃើញក្មេងស៊ីឈ្នួលខ្ញុំខ្លោចចិត្ត
តែងគិតឈឺឆ្អាលជួយឈឺចាប់ ។

២-	សព្វថ្ងៃ ខ្ញុំខំសាងវាសនា
សង្ឃឹមថ្ងៃណាទោះយូរឆាប់
ថាក្រគង់ផ្លាស់ច្បាស់ក្រឡាប់
ប្រញាប់ព្រួយថ្វីនៅ«ក្មេង»ដែរ (១) ។

៣-	ចង់គ្រាន់ តែខ្ញុំបារម្ភណាស់
ក្រែងចិត្តខ្ញុំផ្លាស់ក្រឡាស់ប្រែ
ចូលដៃក្រុមនោះដូចគេដែរ
រួចបែរគ្រហឹមដាក់មិត្តចាស់ ។

៤-	ប្រសិនគ្រប់គ្នាតែបែបហ្នឹង
រៀនសូត្រចេះដឹងចិត្តក្រឡាស់
មិនបើកភ្នែកគ្នាឲ្យឃើញច្បាស់
ស្រឡះតែម្ដងអស់ផ្លូវហើយ !...

ភ្នំពេញ ២២ កក្កដា ៦៥

(១) ស្រីហិតោបទេសថា ៖ បើរកទ្រព្យ-រកវិជ្ជា ត្រូវគិតថាខ្លួនមិនចាស់ មិនស្លាប់, បើរកធម៌ត្រូវគិតថាខ្លួនត្រូវម្រឹត្យុក្រប្ដួចសក់បោកសម្លាប់ឥឡូវហើយ។

## ឱ្យខ្ញុំសប្បាយដូចម្ដេចកើត?

១- នៅក្រុងខ្ញុំឃើញគេសប្បាយ
សម្បូរណ៍ប្រាក់ចាយឫកហ៊ឺហា
ឡានថ្មីផ្ទះថ្មល្អអស្ចារ្យ
កុនល្ខោនស្រីស្រាស្រើបច្រៀងរាំ ។

២- មកស្រែខ្ញុំឃើញអ្នកស្រុកក្រ
ខ្វះស្រូវអង្ករត្រដរខំ
រកត្រីបន្លែជួញដូរផ្សំ
នឿយហត់គ្រៀមក្រំព្រោះអត់ឃ្លាន ។

៣- ឆ្ងាយណាស់! ឆ្ងាយដូចដីនិងមេឃ
ឆ្ងាយពេកវាងក្រនិងមាន
កាលណាទើបទេពតាប្រទាន
ឲ្យមនុស្សសុខសាន្តប្រហែលគ្នា ?

ក្រុងតាកែវ ២២ សីហា ៦៨

## «នគរធ្វើចម្លែក
## សប្បាយតែភ្នែក
## ក្នុងចិត្តវេទកម្ម»

(ក្រមង៉ុយ)

១- នគរធ្វើផ្ថានបានចម្រើន
ផ្ទះថ្មក៏ច្រើនលូតកប់មេឃ
រថយន្តតូចៗច្រើនជ្រុលពេក
មនុស្សដេក«ផ្សងព្រេង»ក៏ច្រើនដែរ ។

២- អ្នកមាន មានស្តុកទ្រព្យក្រៃក្រាស់
អ្នកក្រ ក្រណាស់ខ្វះគ្មានល្វែ
អ្នកមានទិញសាច់គោឲ្យឆ្កែ
អ្នកស្រែម្ចាស់គោស៊ីប្រហុក ។

៣- កូនលោកអ្នកមានរៀនសាលា
សប្បាយហ៊ឺហារីតរីកមុខ
កូនសិស្សក្រខ្សត់ខ្វះស៊ីចុក
កើតទុក្ខខ្វះលុយបង់សាលា ។

៤-	អ្នកខ្យល់ត្រូវក្តោងប៉ោងហោប៉ៅ
ហិចហើរហក់ទៅផ្លូវបនបារ
អ្នកប្រាក់ខែ«ផាប់»គេរាប់ថា
ជាមនុស្សយ៉ាបធាខ្វះអង្ករ ។

៥-	សប្បាយមែនហើយលោកអ្នកមាន !
អ្នកក្រវាល់លានតឹងណែនក
ខំស្ទីតរកខ្យល់ស្ទីងក្អែកស
ត្រដរស្រែកថា «សប្បាយណាស់ ! » ។

ភ្នំពេញ ២៤ កក្កដា ៦៥

# ទឹកដីក្រមអ៊ុំ

១- ជម្មជាតិដែនដួងចិត្តកវី
សប្បាយនឹងដីវែងអន្ទាយ
នឹងទឹករលករលោមសាយ
នឹងមេឃខ្ពស់ឆ្ងាយដូចឆ្ងាយស្នេហ៍ ...
២- តាង៉ុយកវីប្រជាជន
ចិត្តធ្ងន់លើរាស្ត្រចម្ការស្រែ
ស្រឡាញ់ពេញចិត្តតែជាតិខ្មែរ
ទុន្នានគ្មានល្ហែឲ្យភ្ញាក់ខ្លួន ។
៣- ឥឡូវលោកតាសម្រាកហើយ
ម្ដេចឡើយសម្រាកក្បែរចិនយួន
រោងកុន ផ្សារដែក សម្រែកផ្ទួន
ជួបជួនស្ទូរស័ព្ទអាប់ខ្មៅខ្មោ ។
៤- នេះឬវង្វាន់នៃកវី
មានប្រជាប្រិយពេញរដ្ឋា
វង្វាន់លាក់ខ្លួនពួនអាត្មា

នៅកណ្តាលផ្សារគ្មានគេស្គាល់ ។

ភ្នំពេញ ១២ កក្កដា ៦៥

កំណត់ចំណាំ

ឈ្មោះផ្លូវតូចមួយសម្រាប់ក្រមង៉ុយ ឈ្មោះវិទ្យាល័យមួយ និងសាលាបឋមសិក្សាមួយសម្រាប់ម៉ូនិក ។

(កំណត់សរសេរថ្ងៃ ១២-១១-៧០)

# តចឬច្រើន ?

១- ចៅអើយ! រូបតាប្រាថ្នាតិច!
ទ្រព្យធនបេះបិចលះជាទាន
បរិច្ចាគអស់ហើយលែងចង់មាន
ដូរសួគ៌និព្វានបានសុខា ។

២- តាអើយរូបចៅប្រាថ្នាច្រើន
ក្រវើនខ្ញីឃ្មាតសព្វកិច្ចការ
ចង់មានតែក្នុងលោកនេះណា
មិនមានប្រាថ្នាសួគ៌និព្វាន ។

ភ្នំពេញ ១៩ មេសា ៦៥

# ព្រះសង្ឃនិមន្តបិណ្ឌបាត្រ

១-　　នៅតាមស្រុកស្រែស្រុកចម្ការ
លេចតាមរុក្ខាមើលឃើញច្បាស់
ពណ៌លឿងភ្លឺថ្លាល្អត្រចះ
ឃើញហើយចិត្តជ្រះថ្លាបំផុត ។

២-　　ព្រះសង្ឃនិមន្តបិណ្ឌបាត្រ
ឃើញសមស្អាងស្អាតបរិសុទ្ធ
គួរនឹកដល់អង្គព្រះសម្ពុទ្ធ
ជាមកុដកំពូលសីលធម៌ ។

៣-　　នៅតាមទីក្រុងមនុស្សដោរជន់
ព្រះសង្ឃនិមន្តត្រាច់គោចរ
បិណ្ឌបាត្រតាមផ្លូវដ៏អ៊ូអរ
ឃើញហាក់មិនល្អមិនសមសួន ។

៤-　　ព្រះសង្ឃនិមន្តផ្គាល់លើដី
អស់លោកប្រុសស្រីខ្មែរចិនយួន
សុទ្ធយានជំនិះជិះរៀងខ្លួន
គាប់ជួនពេលខ្វះចង់ប៉ះផង ។

៥-	ហ្នឹងហើយក្រុងធំមនុស្សច្រុំច្រើន
ខ្ពង់ខ្ពស់ខ្វាំងឡើងជាចម្បង
នៅស្រែមនុស្សល្ងង់ទាបកន្ទង
តែសមគ្មានផ្គងក្នុងឥរិយា ។

ក្រុងតាកែវ ២៥ សីហា ៦៥

## សម្រាកមួយភ្លែត

១-	ឈប់សិន! ឈប់សិន! វិទ្យាសាស្ត្រ
លឿនណាស់! លឿនណាស់! ចក្រអ្នកឯង
ខ្ញុំខំដាយតាមហត់ហួងហែង
សុំឈប់ប្រជែងផ្អាកចលនា ។

២-	ខ្ញុំក្រាលស្លឹកឈើក្រោមម្លប់ស្វាយ
ដាក់កាយទម្រេតកើយក្រមា
ខ្យល់បក់ល្វៀកៗល្ហើយកាយា
ចិន្តាហោះហើរហិចទៅឆ្ងាយ... ។

៣-	កាលដើមចង្វាក់នៃជីវិត
ហាក់ឥតរន្ធើនក្តៅក្រហាយ
រង្វើលៗលយអន្ទាយ
សប្បាយហូរហែតាមធម្មតា ។

៤-	រទេះគោបរង៉េតង៉ត
ត្រេតត្រយទ្រុយៗកាត់ព្រឹក្សា
សូរស័ព្ទសត្វយំឆ្លងឆ្លើយគ្នា
កំព្រាដួងចិត្តដូចនេនទុំ ។

៥-	ឯនាយដងទង់ចុងជហ្វា
ដំបូលវិហារកុដិមួយដុំ
លេចតាមចន្លោះដើមឈើជុំ
មើលឃើញជ្រងំសមជ្រះថ្លា ។
៦-	ឯនុ៎ះដំណែលប្រាង្គប្រាសាទ
ស្អាងស្អាតសុទ្ធសឹងក្បាច់សិលា
មិនដឹងប៉ុន្មានតដូនតា
ឥឡូវព្រឹក្សាដុះព័ទ្ធព័ន្ធ ...
ភ្នំពេញ ៣ កក្កដា ៦៥

៧-	កាលគ្មានទឹកកកមនុស្សគិតថា
ផឹកទឹកស្រះថ្លាឆ្ងាញ់ណាស់ហើយ
កាលគ្មានឡានលឿនមនុស្សព្រងើយ
ដើរលេងរំហើយគ្មានប្រញាប់ ។
៨-	ក្រុងរីកធំឡើងត្រូវទិញខ្យល់
ទិញសព្វគ្មានសល់គ្រប់ប្រដាប់
ទិញណាស់ខ្វះណាស់ខ្វល់ស្ទើរស្លាប់
ស៊ីណាស់រឹតឆាប់ឃ្លានមកវិញ ។

៩-	ចម្រើនសម្រាប់តែចម្រើន
គិតទៅគ្មានកើនលើសជាថ្មី
ខំលួតនាំហត់អត់បានអ្វី
គួរតែលែងខ្វីរត់តាមទៀត ។

ក្រុងតាកែវ ២២ សីហា ៦៥

# រកស្ងប់គេថាចាញ់

១-	ខំរក រកណាស់ រឹតខ្វះណាស់
ខំរៀនដល់ចាស់នៅមិនចប់
បាននេះខ្វះនោះមិនចេះសព្វ
មិនស្កប់តណ្ហាមនុស្សសម័យ ។
២-	ចង់ដកខ្លួនថយរស់ដោយព្រៃ
ជីវភាពប្រពៃសប្បាយក្រៃ
រស់តាមធម្មជាតិរាល់ខែថ្ងៃ
ចិត្តលៃងចង្រៃអន្ទះសា ។
៣-	តែធ្វើដូច្នេះគេថាចាញ់
មិនខ្មេះរត់ខ្លាញ់ពួនអាត្មា
ថែមគេមើលងាយនិយាយថា:
វាអន់បានជានៅក្នុងព្រៃ ។
ភ្នំពេញ ២៣ កក្កដា ៦៥

# អាសូរដើមដូង

១- យូរហើយដូងដុះក្នុងភូមិម្ត
ដើមធាងលូតល្អមានផ្លែផ្កា
ស្រាប់គេផ្តាច់ឫសផ្តាច់អាហារ
គេថាគាស់ដឹកយកទៅដាំ! ។

២- ល្ងាចនេះដូងដុះក្បែរសាលា
លោកអ្នករាជការខំថែទាំ
តុបតែងស្រោចទឹកយ៉ាងជោគជាំ
ថ្នាក់ថ្នមមុតមាំខ្វាចដូងដួល ។

៣- ព្រឹកឡើងបុណ្យសម្ពោធសាលា
មនុស្សម្មូលខៀវខ្វាមីរខ្វាញ់ខ្វល
ញញឹមប្រិមប្រិយចាំទទួល
ស្រុះស្រួលចោមជុំសម្តេចឪ ។

៤- ដើមដូងដាច់ឫសសប្បាយដែរ
រេរាំហូរហែតាមក្បែរផ្លូវ
ញញឹមស្វាគមសម្តេចឪ
មើលអស់លោកត្រូវបានមេដៃ ។

៥-	ព្រឹកដ៏រីករាយកន្ទង់ទៅ
ដូងនៅម្នាក់ឯងកណ្ដាលថ្ងៃ
សូរ្យសែងក្ដៅដុតគ្មានសំចៃ
ដូងក្សៀយចោលរូបកណ្ដាលក្រុង ។
ភ្នំពេញ ១២ កក្កដា ៦៥

# ស្តាយដួងចន្ទ្រា

១- ខ្ញុំស្រឡាញ់ដួងចន្ទ្រាពេញបូណ៌មី
រឿងរង្សីភ្លឺត្រចះច្បាស់មេឃា
ស្អាតបរិសុទ្ធមូលក្រឡង់ក្នុងនភា
ខ្ញុំនិទ្រាមិនលក់ឡើយពេលរាត្រី ។

២- ខ្ញុំស្រឡាញ់ដួងចន្ទ្រាភ្លឺត្រជាក់
ពន្លឺប្រាក់ស្រោបដួងចិត្តជនប្រុសស្រី
ឲ្យសប្បាយភ្លើតភ្លើនចិត្តឥតខ្វល់អ្វី
ភ្លេចក្រក្រីក្តីសោកសៅក្នុងជីវិត ។

៣- ខ្ញុំស្រឡាញ់ដួងចន្ទ្រាមូលក្រឡង់
ហាក់ដូចវង់ភក្ត្រកល្យាណគូស្នេហ៍ស្និទ្ធ
នាងញញឹម ខ្ញុំសង្ឃឹម សប្បាយចិត្ត
ហាក់បានជិត រឹតរួមរក្ស ស្ម័គ្រគនិដ្ឋា ។

៤- ខ្ញុំស្រឡាញ់ដួងចន្ទ្រាជាសាក្សី
នៃសេចក្តីស្មោះស្ម័គ្រចិត្តស្និទ្ធស្នេហា
នៃក្រមុំនិងកំលោះគូសង្សារ
ដែលប្រាថ្នាបានជាគូរួបរួមកាយ ។

៥-	ខ្ញុំស្រឡាញ់ដួងចន្ទ្រាជាល្បែងក្មេង
ម្ដាយពោលលេងឲ្យកូនតូចពនសុំបាយ
សុំសម្ល, ទឹកបំពង់, ចេក, ដូង, ស្វាយ
កូនសប្បាយញ៉ាំចិបៗសើចក្អឹកៗ ។

៦-	ខ្ញុំស្រឡាញ់ដួងចន្ទ្រាមានពោធិធំ
ជីដូនខ្ញុំប្រាប់ដូច្នេះមកជាញឹក
មើលទៅឃើញមានឫសគល់ដើមមែកស្ទឹក
ក្រោមពោធិព្រឹក្សដូនចាស់រវៃអំបោះ ។

៧-	ខ្ញុំស្រឡាញ់ដួងចន្ទ្រាហៅសសាង្ក
ព្រះឥន្ទ្រស្អាងរូបទន្សាយទុកនៅនោះ
រំឭកកាលពោធិសត្វគិតសង្គ្រោះ
ព្រាហ្មណ៍ដោយស្ទុះលោតចូលភ្លើងជាអាហារ ។

៨-	ខ្ញុំស្រឡាញ់ដួងចន្ទ្រាហៅលោកខែ
នៅស្រុកខ្មែររាជពិធីដ៏ថ្លៃថ្លា
អកអំបុកផើយមើលចំដួងចន្ទ្រា
បន់ទេវតាសូមខេមរាបានថ្កើងថ្កាន ។

៩-	ខ្ញុំស្រឡាញ់ដួងចន្ទ្រានៃកវី (១)
ក្នុងរាត្រីនាំអារម្មណ៍ឲ្យក្សេមក្សាន្ត

ខ្លួនរំភើបហាក់អណ្តែតទៅឆ្ងាយបាន
ភ្លេចខ្លួនប្រាណសប្បាយតាមការស្មើ ។

១០- ខ្ញុំតូចចិត្តនឹងពួកអ្នកវិទ្យាសាស្ត្រ
ម្តេចក៏ផ្តាសធ្វើកាំជ្រួចបាញ់ពីដី
ចង់ទៅយកដួងព្រះចន្ទ ពិភពថ្មី
ហេតុចង់ល្បីខ្លាយកេរ្តិ៍ឈ្មោះបោះនាមា។

១១- ខ្ញុំមិនចង់ឲ្យមនុស្សលោកសុទ្ធហ្មងសៅ
ដូចផ្សែងខ្មៅទៅប្រឡាក់ដួងចន្ទ្រា
ដែលបរិសុទ្ធផុតមន្ទិលផងនានា
គួរបូជាស្រឡាញ់ស្មោះពីហឫទ័យ ។

១២- ឱ!សែនស្តាយដួងចន្ទ្រាជាសកល
ដែលតែងផ្តល់គ្រប់បំណងដោយប្រពៃ
ម្តេចឡើយអ្នកវិទ្យាសាស្ត្រគិតបំភ្លៃ
យកចន្ទ្រថ្លៃជាកម្មសិទ្ធិឲ្យសៅហ្មង ។

---

(១) អត្ថបទតទៅនេះរហូតចប់ត្រូវបានសូត្រក្នុង
ពិធីចែករង្វាន់នៅវិមានរដ្ឋាភិបាល ។
ភ្នំពេញ ២៦ មិថុនា ៦៩

# ជីវិតនិស្សិត

ទំព័រខាងក្រោយតទៅនេះ ជាអត្ថបទកំណាព្យដែលខ្ញុំស្រង់ពីស្នាដៃទី១របស់ខ្ញុំឈ្មោះ «ជីវិតនិស្សិត»។ ដូចខ្ញុំបានជំរាបអ្នកអានហើយថា ដោយស្នាដៃនេះខ្វះពេក ខ្ញុំមិនបោះពុម្ពទេ ប៉ុន្តែខ្ញុំស្តាយអត្ថបទខ្លះដែលខ្ញុំស្រឡាញ់ ដូច្នេះបានជាខ្ញុំស្រង់អត្ថបទខ្លះនោះមកបញ្ចូលក្នុងសៀវភៅនេះផង។

បើអត្ថបទទាំងនោះមិនមានប្រយោជន៍ចំពោះអ្នកអានទេ ខ្ញុំសុំគ្រាន់តែទុកវាសម្រាប់រំឭកអនុស្សាវរីយ៍មួយទៅចុះ។

គ.ស.

## នឹកផ្ទះ (១)

១- នៅសល់បីថ្ងៃ តែយូរពេកក្រៃ
បីថ្ងៃកើតទុក្ខ ជិតរំាកផ្ហើយ
ម្ដេចឡើយ«ជាប់គុក» គួរបានរីកមុខ
បានទៅកំសាន្ត ។

២- កំសាន្តសប្បាយ ជួបមិត្តទាំងឡាយ
ដែលយើងធ្លាប់បាន រស់ជាមួយគ្នា
នោះវិញមិនខាន ហៅសែនសុខសាន្ត
សម្រានចិន្តា ។

៣- យើងកូនអ្នកស្រែ សប្បាយណាស់ដែរ
ប្រញាប់ម្ចីម្នា វិលទៅស្រុកវិញ
ជួបមិត្តមីងមា ម៉ែឪយាយតា
គ្រួសាររីករាយ ។

៤- នឹងជួបមាន់ទា ជួបគោក្ដែឆ្មា
ដែលនៅឯនាយ ដែលធ្លាប់ស្រឡាញ់
ធ្លាប់ខឹងជេរវាយ នឹងឃើញទ្រង់ទ្រាយ
ដីស្រែឡើងវិញ ។

៥- តាអើយ! រូបចៅ    តាំងពីបែកទៅ
នៅឯភ្នំពេញ    តែងនឹកមកតា
ឯទីនេះវិញ    ទទូចទន្ទេញ
ចង់តែមកជួប ។

៦- យាយអើយ! រូបចៅ    តាំងពីបែកទៅ
អស់យូរខែខួប    តែងនឹកមកយាយ
ចង់តែមកជួប    ព្រោះខានបានរួប
រួមសំដីយូរ ។

៧- ឪអើយ! កូននឹក    ទាំងល្ងាចទាំងព្រឹក
បន់ឲ្យតែគ្រូ    ឱយឈប់កាលណា
នឹងបានគិតគូរ    មកផ្ទះឲ្យយូរ
ជួបជុំគ្រួសារ ។

៨- ម៉ែ! ម៉ែ! ម៉ែ! ម៉ែ!    កូននឹកគ្មានល្ហែ
បែកម៉ែថ្ងៃណា    កូនស្រក់ទឹកភ្នែក
នឹកម៉ែអស្ចារ្យ    ម៉ែធ្លាប់រក្សា
ថ្នាក់ថ្នមរូបកូន ។

៩- ឯណាប្អូនខ្ញុំ    ប្អូនតូចប្អូនធំ
បាត់ទៅណាសូន្យ    អូ! នោះមកហើយ

មក! មក! អាអូន　　បងនឹកមកប្អូន
ឯងរាល់គ្នាណាស់ ។
១០- គោយើងនៅទេ?　　ទាំងកូនទាំងមេ
មេក្មេងមេចាស់　　ចុះអាពពាល
តើវានឹកម្ចាស់　　ដើមនៃវាខ្លះ
ដែរឬគ្មានទេ ។
១១- ឆ្កែបងអាលូ　　ខានឃើញវាយូរ
ព្រោះគ្មានទំនេរ　　ខាននាំវាចេញ
ដេញសត្វដូចគេ　　ម៉ូះវាល្អចដេរ
បងខ្លះទេដឹង ។
១២- ឯណារទេះ　　ដែលបងធ្លាប់ជិះ
មានចងកណ្ដឹង　　រទេះគោលឿន
បរបត់ក្បែរស្ទឹង　　រួចទៅក្បែរបឹង
ទៅមើលស្រូវស្រែ ។
១៣- ម៉េចទៅឆ្នាំនេះ　　បានផលគ្រាន់បេះ
ច្រូតកាត់ខ្លះដែរ　　ឬមួយស្កកអស់
ពាសពេញទាំងស្រែ　　ដោយពីរបីខែ
គ្មានឃើញភ្លៀងសោះ ។

១៤- ទាំងក្រុមគ្រួសារ ទាំងញាតកា
ក្មេងចាស់ទាំងអស់ ទាំងជ្រូកមាន់ទា
ខ្ញុំស្រឡាញ់ស្មោះ ចំពោះឥតខ្ចោះ
ដាងអ្វីនានា ។

១៥- ព្រោះអ្នកទាំងនេះ ដែលបានចេះវិះ
ទាំងអស់គ្រប់គ្រា ស្រឡាញ់ខ្ញុំពិត
ឲ្យមកសិក្សា ចំណេះវិជ្ជា
ដារស្មើប្រាណ ។

១៦- វិជ្ជាជាទ្រព្យ យ៉ាងប្រសើរគាប់
គួររកឱ្យបាន ត្រូវខំរៀនសូត្រ
ឲ្យចេះចំណាន ថ្ងៃក្រោយទៅបាន
ក្សេមក្សាន្តជីវិត ។

វត្តកែវព្រះភ្លើង មេសា ៥៨

(១) កំណាព្យនេះកាលសរសេរខ្ញុំដាក់ឈ្មោះថា «គិតទុកបីថ្ងៃមុន» ឥឡូវខ្ញុំសុំកែឈ្មោះថា «ទឹកផ្ទះ» វិញ។ កំណាព្យនេះត្រូវបានសូត្រក្នុងពិធីបែករង្វាន់នៅក្នុងវាំង។

# លាការសិក្សា

១- សព្វថ្ងៃខ្ញុំក្តី　　អារម្មណ៍ខ្ញុំហើរ
ហោះហិចទៅឆ្ងាយ　　គ្មានទីកំណត់
កត់យកសប្បាយ　　ព្រួយចិត្តព្រួយកាយ
សំណាងមិនល្អ ។

២- ខ្ញុំនឹកសង្វេគ　　តែងព្រួយចិត្តពេក
ព្រួយព្រោះខ្លួនក្រ　　រៀនបានតិចតួច
ខំទាំងត្រដរ　　ឥឡូវនេះក៏
ត្រូវតែឈប់រៀន ។

៣- ចេញពីសាលា　　ចោលការសិក្សា
ចោលអស់របៀន　　លាអស់ពួកមិត្ត
លាគ្រូបង្រៀន　　លាទាំងគ្រឹះស្ថាន
ដែលធ្លាប់សិក្សា ។

៤- លាហើយណាមិត្ត　　ខ្ញុំលាអ្នកពិត
ចេញពីសាលា　　លាទាំងអាល័យ
ឥតបីនឹងថា　　ខ្ញុំត្រូវចាប់ការ
ចិញ្ចឹមជីវិត ។

៥- ព្រោះខ្ញុំនេះក្រ គ្មានលុយបន្ត
ការសិក្សាពិត ត្រូវតែចាប់ការ
ចិញ្ចឹមជីវិត លាហើយណាមិត្ត
អ្នកនៅរៀនចុះ ។

៦- ខំទៅសម្លាញ់ រៀនយកឈ្នះចាញ់
ខំទាំងស្រីប្រុស ខំរៀនដើម្បី
ល្បាញល្បីកេរ្តិ៍ឈ្មោះ ត្រូវមិត្តខំលុះ
ទម្លុះអវិជ្ជា ។

៧- អវិជ្ជាគ្មានជោគ គឺជាមេរោគ
ចង្រៃមហិមា តែងស៊ីខួរក្បាល
មនុស្សគ្រប់គ្នា លុះតែស្ទុះស្ទា
រៀនទើបចៀសបាន ។

៨- វិជ្ជាជាថ្នាំ មិត្តអើយចូរចាំ
ខំរកឱ្យបាន ចៀសភាពល្ងិតល្ងង់
ដែលនាំថោកប្រាណ ទើបយើងនឹងបាន
ជាពលរដ្ឋល្អ ។

៩- ខ្ញុំដឹងខ្លួនដែរ ខ្ញុំខំគ្មានល្ហែ
តែដោយខ្លួនក្រ រុលទៅមិនរួច

ព្រោះក្រកីកក្រ		បានជាខ្ញុំចរ
ចាកការសិក្សា ។

១០- ខ្ញុំលាមិត្តទៅ		ចិត្តខ្ញុំចាំនៅ
នឹងមិត្តគ្រប់គ្នា		សង្ឃឹមជានិច្ច
ថាមិត្តមិនរា		បំពេញវិជ្ជា
ទុកសម្រាប់ខ្លួន ។

១១- ឯរូបខ្ញុំវិញ		ខ្ញុំពេញទោម្នេញ
ដោយទឹកស្តាយខ្លួន		រៀនមិនបានច្រើន
គ្មានបេះមាំមួន		មិនបានសមសួន
ចំនួនចំណង់ ។

១២- តែទោះយ៉ាងណា		ត្រង់ការសិក្សា
ខ្ញុំមិនលះបង់		ខ្ញុំខំរៀនទៀត
លុះត្រាអស់ចង់		សូមឱ្យមិត្តស-
ង្ឃឹមជឿខ្ញុំចុះ ។

ភ្នំពេញ មេសា ៥៨

# សម្រេចចិត្ត

១- គិតទៅគេងទៅនៅតែព្រួយ
ជីវិតខ្ញុំមួយគ្មានវាសនា
ជីវិតខ្ញុំមួយតើយ៉ាងណា
គ្មានបានសិក្សាច្រើនជ្រៅជ្រះ ។

២- គិតផងគេងផងគងថ្វាសគិត
ផ្ទះនៅមិនជិតរឹតឃើញផ្ទះ
ច្បាស់ណាស់ជីវភាពឃើញជាក់ច្បាស់
ក្រីក្រកម្មក្រាស់ពេញក្រក្រី ។

៣- ចិត្តអាណិតគ្រួសារខ្វោចចិត្ត
ស្ដីទៅព្រួយចិត្តមិនបេញស្ដី
ខ្វីអស់គំនិតនាំគិតខ្វី
ទ្រាំមិនគិតអ្វីស៊ូតែទ្រាំ ។

៤- រៀនពីរបីឆ្នាំពេលមករៀន
ក្រំក្រៀមឥតមានស្រាកក្រៀមក្រំ
ខំណាស់ខាងរៀនស្គាល់ពីខំ
រៀនដោយសន្សំខំប្រឹងរៀន ។

៥-　　គ្រួសារក្រណាស់ក្រមួយគ្រួ
គ្មានទ្រព្យល្អគួរសមរកគ្មាន
មានតែស្រូវស្រែទ្រព្យដែលមាន
បានជាទ្រាំរៀនទៅមិនបាន ។

៦-　　ចំណេះតិចតួចស្តួចចំណេះ
ក្សាន្តបានដែរអេះ សុខក្សេមក្សាន្ត
សាន្តសុខជីវិតឥតសុខសាន្ត
ធ្វើអ្វីទៅបានការអ្វីធ្វើ ។

, , , , ,

១០-　　មានតែផ្លូវមួយផ្លូវមានមួយ
វង់ចាំជំហានកុំវេរង់
ខ្វង់ក៏មិនមែន មិនមែនខ្វង់
ធ្វើគ្រូខ្ញុំចង់ត្រូវតែធ្វើ ។

, , , , ,

១៧-　　មិត្តអើយមើលទៀននៅផ្ទះមិត្ត
ឆាប់ឆេះមិត្តអុជទៀនឆេះឆាប់
ស្រាប់វិនាសរូបមិត្តឃើញស្រាប់
រាងរូបទៀនស្លាប់បាត់រូបរាង ។

១៨-　ទៀនវិនាសពិតប៉ុន្តែទៀន
រាងរៃមែនមានគិតរៃរាង
ទៀងដាក់បំភ្លឺគេដាក់ទៀង
ភ្លឺគេបំព្រាងឱ្យគេភ្លឺ ។

១៩-　ការធ្វើគ្រូគេគឺជាការ
ឮហើយគេថាយើងធ្លាប់ឮ
ឈឺចាប់មានរោគជួនកាលឈឺ
ឲ្យតែសិស្សភ្លឺដោយគ្រូឲ្យ ។

២០-　ទៀនដូចជាគ្រូគ្រូដូចជាទៀន
ខ្សោយរូបសុខភាពតែងអន់ខ្សោយ
ក្រោយទៅរឹងខ្លួនជាខាងក្រោយ
ភ្លឺចុះខ្ញុំឲ្យសិស្សបានភ្លឺ ។

មេសា ៥៨